**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៧៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ នៅជាតំបន់ប្រើប្រាស់ដោយចីរភាព

PheakdeyLaw Book Store

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពី តំបន់ការពារធម្មជាតិ

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ

-យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។

## ស ម្រេ ច

**មាត្រា១.-**

ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ឧទ្យានជាតិបុទុមសាគរ លើផ្ទៃដីទំហំ ៩.១០០ហិកតា(ប្រាំបួនពាន់មួយរយហិកតា) ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតក្នុងភូមិសាស្ត្រខេត្តកោះកុង សម្រាប់ផ្តល់

www.pheakdeylaw.com

ជូនក្រុមហ៊ុន Union Development Group Co.,Ltd ធ្វើការវិនិយោគអភិវឌ្ឍន៍អាងស្តុកទឹក និង វារីអគ្គិសនី ដែលមានលិខិតលេខ ៨៤៥ សជណ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ និងមានទីតាំង និងនិយាមកាដូចមានក្នុងផែនទីភ្ជាប់ជាឧបសម្ព័ន្ធ។

**មាត្រា២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសាផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អភិបាល នៃគណៈអភិបាលខេត្តកោះកុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែសីហា ឆ្នាំ ២០១១

រាជរដ្ឋាភិបាលនាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បណ្ណាគារ ភក្តីឡដ៏
PheakdeyLaw Book Store

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
  «ដើម្បីគោរពជូនជ្រាប»
- ដូចមាត្រា ៣ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

ផែនទី ទីតាំងដីវិនិយោគសាងសង់អាងស្តុកទឹក និងវារីអគ្គិសនី របស់ក្រុមហ៊ុន Union Development Group Co.,Ltd

លើផ្ទៃដីទំហំ ៩១០០ ហិកតា ក្នុងឧទ្យានជាតិបូទុមសាគរ ស្រុកកិរីសាគរ ខេត្តកោះកុង

អនុក្រឹត្យលេខ..........................

ថ្ងៃទី .........ខែ..........ឆ្នាំ ២០១







| Ord | ID | Coo_x | Coo_y |
|---|---|---|---|
| 1 | S | 300000 | 1210000 |
| 2 | T | 306026.78 | 1210000 |
| 3 | D | 302000 | 1232000 |
| 4 | E | 302000 | 1226000 |
| 5 | F | 300000 | 1224000 |
| 6 | G | 300000 | 1222000 |
| 7 | H | 302000 | 1222000 |
| 8 | I | 302000 | 1216000 |
| 9 | J | 300000 | 1216000 |
| 10 | K | 300000 | 1206000 |
| 11 | L | 302000 | 1206000 |
| 12 | U | 300000 | 1214000 |
| 13 | V | 305921 | 1214000 |
| 14 | W | 307025 | 1222490 |

Indian_1960_UTM_Zone_48N

1:30,000

www.pheakdeylaw.com